# ពេលដែលត្រូវប្រើឧបករណ៍ធ្វើតេស្តកូវីដ-១៩ ដោយខ្លួនឯង

* សូមអនុវត្តតាមការណែនាំរបស់ផលិតផលជាជំហានៗ និងការប្រុងប្រយ័ត្ន ដែលរួមបញ្ចូលជាមួយឧបករណ៍ធ្វើតេស្តដោយខ្លួនឯងរបស់អ្នក។



ប្រសិនបើអ្នកមានជំងឺកូវីដ-១៩ ក្នុងរយ:ពេល ៩០ ថ្ងៃចុងក្រោយ អ្នកមិនចាំបាច់ធ្វើតេស្តទេ លុះត្រាតែអ្នកមានរោគសញ្ញាថ្មីៗ។




ប្រសិនបើអ្នកមានរោគសញ្ញានៃជំងឺកូវីដ-១៩ សូមអ្នកដាក់ខ្លួនអ្នកឯងឱ្យនៅដាច់ដោយឡែកពីអ្នកដទៃ ហើយត្រូវធ្វើតេស្តឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដោយមិនគិតពីស្ថានភាពនៃការចាក់វ៉ាក់សាំងនោះទេ។



ប្រសិនបើអ្នកបានទាក់ទងជាមួយអ្នកដែលមានជំងឺកូវីដ-១៩សូមធ្វើតេស្តយ៉ាងហោចណាស់ ៥ ថ្ងៃពេញបន្ទាប់ពីការប៉ះពាល់អ្នកជំងឺនោះ។

- សូមពាក់ម៉ាសដែលមានល្មមសមរម្យរយ:ពេល ១០ ថ្ងៃពេញ ពេលនៅជុំវិញអ្នកផ្សេងទៀត នៅក្នុងផ្ទះ និងនៅខាងក្នុងទីសាធារណ:។
- សូមសង្កេតរកមើលរោគសញ្ញា។ សូមធ្វើតេស្តប្រសិនបើអ្នកមានរោគសញ្ញា ហើយធ្វើតាម ការណែនាំសម្រាប់ករណីមានជំងឺ និងមានទំនាក់ទំនងជាមួយអ្នកមានជំងឺ ( ស្កេនកូដ QR ខាងក្រោម ) ។



សូមពិចារណាលើការធ្វើតេស្តមុនពេលចូលរួមក្នុងព្រឹត្តិការណ៍នៅទីខាងក្នុង ឬការជួបជុំគ្នា។

- សូមធ្វើតេស្តភ្លាមៗមុនពេលមានការជួបជុំ ឬមុនជិតដល់ម៉ោងនៃព្រឹត្តិការណ៍តាមដែលអាចធ្វើទៅបាន។ ធ្វើតេស្តមុនពេលចំណាយពេលជាមួយគូពូណា ( Kupuna ) ឬអ្នកដែលមានហានិភ័យខ្ពស់ក្នុងការឈឺខ្លាំង។

## អ្វីដែលត្រូវធ្វើប្រសិនបើអ្នកធ្វើតេស្តវិជ្ជមានជំងឺកូវីដ-១៩៖



ដាក់ខ្លួនឱ្យនៅដាច់ដោយឡែកពីអ្នកដទៃ រយ:ពេល ៥ ថ្ងៃ។

- សូមមើលការណែនាំសម្រាប់ករណីមានជំងឺ និងមានទំនាក់ទំនងជាមួយអ្នកមានជំងឺ ( ស្កេនកូដ QR ខាងក្រោម ) ។



ពាក់ម៉ាសដែលមានល្មមសមរម្យរយ:ពេល ១០ ថ្ងៃពេញ ពេលនៅជុំវិញអ្នកផ្សេងទៀតនៅក្នុងផ្ទះ និងនៅខាងក្នុងទីសាធារណ:។



សូមតាមដានរោគសញ្ញារបស់អ្នក ហើយទាក់ទងទៅអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកប្រសិនបើចាំបាច់។

- សម្រាប់ការសង្គ្រោះបន្ទាន់ផ្នែកវេជ្ជសាស្ត្រ - ការពិបាកដកដង្ហើម ឈឺទ្រូង ឬរោគសញ្ញាត្រូវសង្គ្រោះបន្ទាន់ផ្សេងៗទៀត - សូមហៅទូរសព្ទទៅ ៩១១ ។



លទ្ធផលដែលធ្វើតេស្តដោយខ្លួនឯងមានវិជ្ជមាន អ្នកមិនចាំបាច់រាយការណ៍ទៅនាយកដ្ឋានសុខភាពរដ្ឋហាវ៉ៃនោះទេ។

## អ្វីដែលត្រូវធ្វើប្រសិនបើអ្នកធ្វើតេស្តអវិជ្ជមានសម្រាប់ជំងឺកូវីដ-១៩ ៖



អ្នកអាចនៅតែមានឱកាសដែលមានជំងឺកូវីដ-១៩ ជាពិសេសប្រសិនបើអ្នកមានរោគសញ្ញានានា ឬបានប៉ះពាល់ជាមួយអ្នកដែលមានជំងឺកូវីដ-១៩។

សូមពិចារណាការធ្វើតេស្តម្តងទៀតពី ២៤ ទៅ ៤៨ ម៉ោងក្រោយ ឬស្វែងរកការធ្វើតេស្ត PCR ។ ការធ្វើតេស្តលើសពី ១ដង អាចជួយអ្នកឱ្យប្រាកដថាអ្នកមិនមានជំងឺកូវីដ-១៩។

### ព័ត៌មានបន្ថែម

- ចូលទៅកាន់ HawaiiCOVID19.com សម្រាប់ការណែនាំបន្ថែម។
- អ្នកអាចទាក់ទងនាយកដ្ឋានសុខភាពរដ្ឋ Hawai`i តាមរយ:លេខ ( ៨០៨ ) ៥៨៦-៨៣៣២ ប្រសិនបើអ្នកមានសំណួរបន្ថែម។

ស្កេនខ្ញុំ សម្រាប់ការណែនាំករណីមានជំងឺ និងមានទំនាក់ទំនងជាមួយអ្នកមានជំងឺ